ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ :......០១៧/២៦.............ក.ប/ស.ជ.ណ.អ.វ.ក

# សេចក្តីជូនដំណឹង
# ស្តីពី
# កាតព្វកិច្ចអនុវត្តរបបស្វ័យប្រកាសអធិការកិច្ចការងារ តាមប្រព័ន្ធស្វ័យប្រវត្តិកម្មក្នុងខែមិថុនា ឆ្នាំ២០២៦

យោងច្បាប់ស្តីពីការងារ និងប្រកាសលេខ៣៥៨/២១ ក.ប/ប្រ.ក.អ.ធ.ក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យដំណើរការរបបស្វ័យប្រកាសអធិការកិច្ចការងារ និងការធ្វើអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារឱ្យបានជ្រាបថា លោក/លោកស្រី មានកាតព្វកិច្ចធ្វើស្វ័យប្រកាសអធិការកិច្ចការងារ ក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មចំនួន ២ (ពីរ) លើកក្នុងមួយឆ្នាំ គឺលើកទី១ នៅក្នុងខែមិថុនា និងលើកទី២ នៅក្នុងខែធ្នូ នៃឆ្នាំនីមួយៗតាមរយៈគេហទំព័រ https://sicms.mlvt.gov.kh។ ក្នុងករណីរបកគំហើញដោយប្រព័ន្ធស្វ័យអធិការកិច្ចការងារបង្ហាញចំណុចមិនត្រឹមត្រូវ ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រត្រូវធ្វើការកែតម្រូវការអនុវត្តរបស់ខ្លួនឱ្យបានត្រឹមត្រូវក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ ។ ប្រសិនបើមិនកែតម្រូវចំណុចល្មើសណាមួយ អធិការការងារនឹងចាត់វិធានការតាមផ្លូវច្បាប់។

ក្នុងករណីខកខាន ឬមិនបានអនុវត្តកាតព្វកិច្ចធ្វើស្វ័យប្រកាសអធិការកិច្ចការងារតាមកាលកំណត់ខាងលើ ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រសាមីត្រូវទទួលរងការផាកពិន័យ និងចំណាត់ការពីអធិការការងារស្របតាមច្បាប់ជាធរមាន។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រទាំងអស់អនុវត្តបានត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ សុក្រ ១៣កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**

**ហេង ស៊ួរ**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*